00505906

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

C22/9/14

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៣២)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ក្រឡាបញ្ជី: ឈុន ព្រលឹង
Entela JOSIFI

កាលបរិច្ឆេទ: ៣០ ខែមេសា ឆ្នាំ២០១០

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 04 / 2010
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ(ដោយកោសលុប)**
**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចលើ ការបន្តរយៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY
យ៉េត ចរិយា
William SMITH
សេង ប៊ុនឃាង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 04 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-អវតក/កសចស (អបជ32)

លេខ/C22/9/14

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

នី ចាន់ឌី
Mahdev MOHAN
Lyma NGUYEN
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Elizabeth-Joelle RABESANRATANA
Annie DELAHAIE
Philippe CANONNE
Martine JACQUIN
Fabienne TRUSSES-NAPROUS
Ms. Françoise GAUTRY
Ms. Isabelle DURAND
Ms. Christine MARTINEAU
Ms. Laure DESFORGES
Mr. Ferdinand DJAMMEN
ឡោ ជុនធី
ស៊ិន សុវ៉ាន
សំ សុខគង់
ហុង គឹមសួន
គង់ ពិសី
គង់ ហេង
Silke STUDZINSKY
Olivier BAHOUGNE
Marie GUIRAUD
Patrick BAUDOUIN
ជេត វណ្ណលី
ពេជ អង្គ
Julien RIVET
Pascal AUBOIN

**សហមេធាវីការពារក្តីជនត្រូវចោទ**

អាង ឧត្តម
Michael G. KARVAVAS

00505908

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) បានទទួល “បណ្តឹងឧទ្ធរណ៍របស់ **អៀង សារី** ប្រឆាំងនឹងដីកាសម្រេចរបស់[សហចៅក្រមស៊ើបអង្កេត]អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន” ដែលសហមេធាវីការពារក្តីជនត្រូវចោទ **អៀង សារី** បានប្តឹងនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩ (“បណ្តឹងឧទ្ធរណ៍”)[១]។

## I. ប្រវត្តិនីតិវិធី

១. អង្គបុរេជំនុំជម្រះយោងទៅលើរបាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង[២] ដែលត្រូវបានពិនិត្យ និងអនុម័ត កាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១០ ដែលបង្កើតជាផ្នែកមួយនៃសាលដីកានេះ។

២. នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន (“ដីកាសម្រេចបន្តថិរវេលា”) ដោយបានសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្នបន្តទៀតលើ **អៀង សារី** ដែលបានជាប់ឃុំ ចាប់តាំងពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧[៣]។ ដីកាសម្រេចបន្តថិរវេលានេះបានជូនដំណឹងទៅភាគីទាំងអស់ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩។

៣. នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ហើយនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ដែលបណ្តឹងឧទ្ធរណ៍នេះបានជូនដំណឹងដល់ភាគីទាំងអស់ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៩។

៤. នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ (“ចម្លើយតបរបស់សហព្រះរាជអាជ្ញា”)[៤]។

៥. នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ (“ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី”)[៥]។

---

[១] បណ្តឹងឧទ្ធរណ៍ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ C22/9/1។

[២] របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ C22/9/8។

[៣] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ C22/8។

[៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីពីការបន្តថិរវេលានៃការឃុំខ្លួន ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ C22/9/2។

៦. នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានទទួលសេចក្ដីសង្កេតលើបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីតំណាងរដ្ឋប្បវេណីដទៃទៀត ("សេចក្ដីសង្កេតរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី")[៦]។ ក្រោយពីធ្វើការពិនិត្យឡើងវិញលើខ្លឹមសារនៃសេចក្ដីសង្កេតទាំងនេះ ហើយក្រោយពីកត់សម្គាល់ឃើញថា ភាគីទាំងឡាយមិនបានផ្ដល់យោបល់ ឬការជំទាស់លើការដាក់ឯកសារយឺតពេល[៧] ដូច្នេះ អនុលោមតាមវិធាន ៣៩(៤)(ខ) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះបានសម្រេចទទួលស្គាល់សុពលភាពនៃឯកសារទាំងនេះ ទោះបីបានដាក់ក្រោយរយៈពេលកំណត់ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង និងសេចក្ដីណែនាំអនុវត្តក៏ដោយ។

៧. នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ប្រធានអង្គបុរេជំនុំជម្រះបានចេញដីកាកំណត់កាលបរិច្ឆេទ បើកសវនាការជាសាធារណៈលើបណ្ដឹងឧទ្ធរណ៍ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០[៨]។ នៅមុនពេលសវនាការ អង្គបុរេជំនុំជម្រះបានទទួលលទ្ធភាពពិនិត្យសំណុំរឿង ដែលបានធ្វើបច្ចុប្បន្នភាពរួចហើយ។

៨. នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានបើកសវនាការជាសាធារណៈមួយ ដែលជនត្រូវចោទមានសហមេធាវីការពារក្ដីរបស់ខ្លួនតំណាង។ សវនាការនេះ បានបើកជំនុំជម្រះជាសាធារណៈ។

## II. ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍

---

[៥] ចម្លើយតបរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ C22/9/3។

[៦] សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី៖ សេចក្ដីសង្កេតចំពោះបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ជំទាស់ទៅនឹងដីកាសម្រេចបន្តចិរវេលាឃុំខ្លួនបណ្ដោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ C22/9/7។

[៧] អង្គបុរេជំនុំជម្រះរៀបរាប់ជាពិសេសចំពោះការដាក់ឯកសារនេះក្នុងពេលសវនាការ លើបណ្ដឹងឧទ្ធរណ៍ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០។ *សូមមើល*ប្រតិចារឹកនៃសវនាការលើបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ C22/9 ទំព័រ១៨។

[៨] ដីកាកំណត់កាលបរិច្ឆេទសវនាការ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ឯកសារ C22/9/4។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

៩. ដីកាសម្រេចបន្តឋិរវេលាបានចេញនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយបានជូនដំណឹងដល់គ្រប់ភាគីនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩។ សហមេធាវីការពារក្ដីជនត្រូវចោទបានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយបានបណ្ដឹងឧទ្ធរណ៍នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩ ក្នុងរយៈពេលកំណត់ដូចដែលបានចែងនៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង")។

## III. ច្បាប់ជាធរមាន

១០. បណ្ដឹងឧទ្ធរណ៍នេះយោងលើវិធាន ៦៣ នៃវិធានផ្ទៃក្នុង។

## IV. លក្ខណៈនៃបណ្ដឹងឧទ្ធរណ៍

១១. យោងតាមបណ្ដឹងឧទ្ធរណ៍ សហមេធាវីការពារក្ដីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ៖

> "បដិសេធដីកាសម្រេចអំពីការបន្តឋិរវេលានៃការឃុំខ្លួន និងបញ្ចប់ការឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន"[៩]។

១២. សហមេធាវីការពារក្ដីបានអះអាងថា លក្ខខណ្ឌសម្រាប់ការឃុំខ្លួន ដែលមានចែងនៅក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង មិនត្រូវបានបំពេញនោះឡើយ ហើយទោះបីជាលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌនានានៅក្នុងវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង បានបំពេញក៏ដោយ សហចៅក្រមស៊ើបអង្កេតបានរំលោភទៅលើឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងការចេញដីកាសម្រេចបន្តឃុំខ្លួន ដោយសារខ្លួនមិនបានពិចារណាទៅលើវិធានការធូរស្រាលជាងនេះ ដែលអាចសម្រេចគោលបំណងតែមួយ[១០]។

១៣. នៅក្នុងសវនាការនាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ សហមេធាវីការពារក្ដីជនត្រូវចោទហាក់ដូចជាដកជំហរទាមទារការដោះលែង ដូចដែលបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍ ដោយបានអះអាងថាខ្លួន"មិនដែលស្នើសុំឱ្យដោះលែង[ជនត្រូវចោទ]ឡើយ" ប៉ុន្តែខ្លួនស្នើសុំឱ្យ"តុលាការផ្លាស់ប្ដូរលក្ខខណ្ឌ

---

[៩] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌចុងក្រោយ។

[១០] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ២៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C C.E.T.C

នៃការឃុំខ្លួនរបស់គាត់ពីការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ទៅជា [...] ការឃុំខ្លួនក្នុងផ្ទះ ឬ [...] ការឃុំខ្លួននៅក្នុងមន្ទីរពេទ្យវិញ"[១១]។

១៤. នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានស្នើសុំអង្គបុរេជំនុំជម្រះឱ្យច្រានចោលបណ្ដឹងឧទ្ធរណ៍ទុកជាឥតបានការ ដោយឈរលើមូលដ្ឋានថា៖ (១) ដើមបណ្ដឹងឧទ្ធរណ៍បានខកខានក្នុងការបង្ហាញឱ្យឃើញអំពីការកែប្រែនៃកាលៈទេសៈជាក់ស្ដែងណាមួយ (២) មិនមានភស្តុតាងដោះបន្ទុកដែលបានរកឃើញថា មានទម្ងន់ជាងភស្តុតាងដែលអាចធ្វើឱ្យអ្នកសង្កេតការណ៍អព្យាក្រឹត្យជឿថា ដើមបណ្ដឹងឧទ្ធរណ៍ អាចធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតនៅក្រោមការស៊ើបអង្កេត (៣) ការចោទប្រកាន់របស់ក្រុមមេធាវីការពារក្ដី ចំពោះប្រតិបត្តិការណ៍នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវបានរកឃើញថាគ្មានសុពលភាពហើយ (៤) លក្ខខណ្ឌដូចមានចែងនៅក្នុងវិធាន ៦៣(៣)(ខ) នៅតែបានបំពេញ[១២]។

១៥. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើន បានសន្និដ្ឋាននៅក្នុងចម្លើយតបរបស់ខ្លួនថា "បណ្ដឹងឧទ្ធរណ៍នេះត្រូវតែបដិសេធចោល។ ដីកាសម្រេចបន្តថិរវេលារបស់[សហចៅក្រមស៊ើបអង្កេត]មានហេតុផលសមរម្យ និងត្រឹមត្រូវ ហើយសហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវ"[១៣]។ យោងតាមសេចក្ដីសង្កេតរបស់ខ្លួន សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដទៃទៀត បានស្នើសុំឱ្យបុរេជំនុំជម្រះឱ្យតម្កល់ដីកាសម្រេចបន្តថិរវេលាទុកជាបានការ ហើយបានសន្និដ្ឋានថា ការដាក់ឱ្យជនត្រូវចោទមានសេរីភាពនៅក្រៅឃុំ "អាចនាំឱ្យមានការពិបាកយល់ពីសំណាក់ប្រជាជន ហើយហានិភ័យសំខាន់ដែលសម្ដែងចេញមករបស់អ្នកទាំងនោះអាចជាការហិង្សា"[១៤]។

---

[១១] ប្រតិចារឹកនៃសវនាការលើបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ C22/9 ទំព័រ២៥។

[១២] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២ កថាខណ្ឌរង ក-ង។

[១៣] ចម្លើយតបរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ២៨។

[១៤] សេចក្ដីអង្កេតរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ២៦-២៧ និងប្រតិចារឹកនៃសវនាការលើបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ទំព័រ៧៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

១៦. ដោយពិចារណាលើសេចក្ដីសម្រេចទាំងឡាយរបស់ខ្លួនទាក់ទងនឹងបញ្ហាឃុំខ្លួន[១៥] និងសេចក្ដីសន្និដ្ឋានរបស់ភាគីដូចបានលើកឡើងនៅក្នុងរបាយការណ៍ស្ដីពីការត្រួតពិនិត្យសំណុំរឿង អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលដីកាសម្រេចបន្តថិរវេលាសារជាថ្មី ត្រង់ចំណុច៖

ក. មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (វិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង)។

ខ. មូលដ្ឋានដែលធ្វើឱ្យការឃុំខ្លួនបណ្ដោះអាសន្នជាវិធានការដ៏ចាំបាច់មួយ(វិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង) ។

គ. ការយកចិត្តទុកដាក់នៅក្នុងការបំពេញកិច្ចស៊ើបសួរ។

ឃ. សំណើសុំដោះលែងដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។

## V. ការពិចារណា

### ក. មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (វិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង)៖

---

[១៥] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ឯកសារលេខ C9/4/7។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ឯកសារ C80/5/18។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការបន្តថិរវេលានាំការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ ឯកសារលេខ C22/5/38 និងសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណុំរឿងដោះលែងឲ្យមានសេរីភាព និងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ C26/5/26។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

១៧. យោងតាមដីកាសម្រេចបន្តថិរវេលា សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឃើញថា យោងតាមដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨[១៦] និងសាលដីការបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩[១៧] លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបអង្កេតបានរកឃើញថា មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា **អៀង សារី** ធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដែលខ្លួនត្រូវបានចោទប្រកាន់[១៨]។

១៨. សហចៅក្រមស៊ើបអង្កេតបានលើកឡើងបន្ថែមទៀតថា ចាប់តាំងពីសវនាការរបស់អង្គបុរេជំនុំជម្រះចុងក្រោយបំផុត លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នាថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានបន្តស៊ើបអង្កេតលើការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយបានបន្តដាក់ភស្តុតាងនៅក្នុងសំណុំរឿង។ សហចៅក្រមស៊ើបអង្កេតបានចង្អុលបញ្ជាក់ថា ចម្លើយសាក្សីថ្មីៗជាងហាសិបបានដាក់ចូលបន្ថែម ដែលចម្លើយទាំងនេះជួយបំភ្លឺថាតើជនត្រូវចោទបានដើរតួនាទីទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ដែរឬទេ[១៩]។

១៩. យោងតាមដីកាសម្រេចបន្តថិរវេលានេះ សហចៅក្រមស៊ើបអង្កេតបានបន្តរៀបរាប់ភស្តុតាងដែលខ្លួនពិចារណាថាមានលក្ខណៈដាក់បន្ទុក[២០]។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ភស្តុតាងមួយចំនួនអាចទំនងជាភស្តុតាងដោះបន្ទុក ប៉ុន្តែសហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញថា ភស្តុតាងដោះបន្ទុកទាំងនេះមិនគ្រប់គ្រាន់ធ្វើឱ្យគ្មានសុពលភាព ចំពោះមូលដ្ឋាននៃមូលហេតុដែលត្រូវ

---

[១៦] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃ១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ C22/4។

[១៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ C22/5/38 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តការឃុំខ្លួន")

[១៨] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ១១-១៣។

[១៩] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ១៥។

[២០] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ១៥ កថាខណ្ឌរង ក-ជ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

00505914



បានរកឃើញ និងជឿជាក់ថា ជនត្រូវចោទអាចធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតនៅក្រោមការស៊ើបអង្កេតឡើយ[២១]។

២០. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា៖

"បន្ទាប់ពីបានពិនិត្យឡើងវិញលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង...នៅត្រឹមដំណាក់កាលនៃកិច្ចស៊ើបសួរនេះ មានការលេចឡើងនូវអង្គហេតុ និងព័ត៌មានបន្ថែមនានា ដែលអាចឱ្យអ្នកសង្កេតការណ៍អព្យាក្រឹត្យអាចជឿជាក់បានថា នៅក្នុងមុខងារ និងតួនាទីមួយ ឬច្រើនរបស់គាត់ ដូចបានបង្ហាញខាងលើ **អៀង សារី** បានរៀបចំផែនការ ញុះញង់ បញ្ជា មិនបានព្យាយាមទប់ស្កាត់ ឬ ជួយ និងជម្រុញឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋកម្មនានា ដូចមានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជាហេតុនាំឱ្យលក្ខខណ្ឌដែលមានកំណត់នៅក្នុងវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុងនៅតែត្រូវបានបំពេញ ចាប់តាំងពីពេលជនរូបនេះត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ទោះបីជាមានការកន្លងផុតទៅនៃពេលវេលាក្ដី"[២២]។

២១. ដោយចង្អុលយោងលើសំណើសុំមួយចំនួនដែលខ្លួនបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ប្រឆាំងនឹងសហចៅក្រមមួយរូប សហមេធាវីការពារក្ដីបានសន្និដ្ឋាននៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួនថា "ការកំណត់តាមរយៈសំណុំរឿងថាពិតជាមាន "មូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់"នោះមិនអាចធ្វើទៅបានទេ ដោយសារតែការមានកំហុសនៅក្នុងកិច្ចស៊ើបអង្កេត [...]"។ សហមេធាវីការពារក្ដីបានសន្និដ្ឋានថា "បញ្ហាទាំងនេះដែលពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរ មិនត្រូវអនុញ្ញាតឱ្យដើម្បីធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទទួលបានសេរីភាពជាសារវន្តរបស់លោក អៀង សារី ឬ សិទ្ធិទទួលបាននូវសច្ចធារណ៍នៃនិរទោសរបស់គាត់ឡើយ"[២៣]។

២២. នៅក្នុងចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា "ភាគីបណ្ដឹងឧទ្ធរណ៍មិនបានបង្ហាញឱ្យឃើញថា តើ[សារណា]នានារបស់ខ្លួនស្ដីពី[ប្រតិបត្តិការការងាររបស់ កសចស]

---

[២១] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌ១៦ និង១៧។

[២២] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌ១៨។

[២៣] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ១២-១៤។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

និងលទ្ធផលដែលមិនបានទទួលជោគជ័យរបស់ខ្លួនមកទល់ពេលនេះ អាចមានភាពគ្រប់គ្រាន់សម្រាប់បង្ហាញអំពី “កំហុស” ណាមួយនោះឡើយ[នៅក្នុងការស៊ើបអង្កេតរបស់ខ្លួន]”។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា “ដើមបណ្តឹងឧទ្ធរណ៍មិនបានបញ្ជាក់ថា តើបាត់មិនឃើញមានឯកសារដោះបន្ទុកអ្វីខ្លះនៅក្នុងសំណុំរឿង ឬថាតើភស្តុតាងណាខ្លះដែល [សចស] អាចមិនបានចាប់អារម្មណ៍ដល់នោះឡើយ”[២៤]។ នៅក្នុងពេលសវនាការនាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ លើបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា មូលហេតុដែលត្រូវបានរកឃើញដែលបង្ហាញថា ជនត្រូវចោទអាចធ្លាប់ប្រព្រឹត្តឧក្រិដ្ឋកម្មដែលខ្លួនត្រូវបានចោទប្រកាន់នោះ “មានលក្ខណៈកាន់តែរឹងមាំឡើង” ដោយសារតែខ្លួននាពេលថ្មីៗនេះត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មជាតិមួយចំនួនទៀត និងទម្រង់នៃការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម[២៥]។

២៣. នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីបានសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍មិនបានជំទាស់នឹងដីកាសម្រេច អំពីការបន្តថិរវេលានៃការឃុំខ្លួនពាក់ព័ន្ធនឹងលក្ខខណ្ឌ ដូចមានចែងនៅក្នុងវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុងទេ[២៦]។ ដើមបណ្តឹងរដ្ឋប្បវេណីបានចង្អុលបញ្ជាក់បន្ថែមទៀតថា ចម្លើយសាក្សីមួយចំនួនដែលត្រូវបានសហចៅក្រមស៊ើបអង្កេតចាត់ទុកថាជាភស្តុតាងដោះបន្ទុក ត្រូវយកមកពិចារណាដោយមានការប្រុងប្រយ័ត្នបំផុត ដូចដែលដើមបណ្តឹងរដ្ឋប្បវេណីបានសន្និដ្ឋានថា សាក្សីដែលបានស្រង់សំដីនេះមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹង **ប៉ុល ពត** និងជនត្រូវចោទ[២៧]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតក៏បានរំលឹកនៅក្នុងសេចក្តីសង្កេតរបស់ខ្លួនផងដែរថា នាពេលថ្មីៗនេះ ជនត្រូវចោទក៏ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ផងដែរ[២៨]។

---

[២៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៩-១០។

[២៥] ប្រតិចារឹកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ C22/9 ទំព័រ៥២។

[២៦] ចម្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ៥។

[២៧] ចម្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ១០។

[២៨] សេចក្តីសង្កេតរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ១៧-១៩។



E.C.C.C * C.E.T.C.
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

២៤. ទាក់ទងនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីលើបទចោទបន្ថែម អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន បានចេញនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ហើយនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចមួយ ដើម្បីឆ្លើយបំភ្លឺអំពីបទចោទដែលដាក់បន្ទុកលើជនត្រូវចោទ។ ដីកាសម្រេចនេះបានជូនដំណឹងជាភាសាអង់គ្លេសដល់ភាគីទាំងឡាយនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨[២៩]។

២៥. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៨ ក្នុងពេលសួរចម្លើយជនត្រូវចោទ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទ និងសហមេធាវីការពារក្តីរបស់ជននេះអំពីបទចោទទាំងឡាយដែលអាចត្រូវបានចោទប្រកាន់ ដោយក្នុងនោះបញ្ជាក់ថា “វាមានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់បានបង្ហាញថា អំពើដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបទល្មើសចែងក្នុងច្បាប់ចែងក្នុងច្បាប់ជាតិ ពិតជាត្រូវបានប្រព្រឹត្តឡើង[៣០]”។ នៅពេលបង្ហាញខ្លួនលើកដំបូង ជនត្រូវចោទទទួលបានការជូនដំណឹងថា ខ្លួនត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យចំពោះអំពើទាំងឡាយដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយបានបញ្ជាក់បទល្មើសនានាដែលដាក់បន្ទុកលើខ្លួន ក្នុងនោះរួមមាន៖ បទល្មើសប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥ មាត្រា៦ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤[៣១]។

២៦. ដើម្បីជាផលប្រយោជន៍យុត្តិធម៌ អង្គបុរេជំនុំជម្រះយោងលើសាលដីកាលើកមុនរបស់ខ្លួន ដែលបានសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងសំណុំរឿងលេខ ០០១

---

[២៩] ដីកាសម្រេចលើ សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការបំភ្លឺ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D198/1 (“ដីកាសុំឱ្យធ្វើការបំភ្លឺ”)។

[៣០] កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D282 កថាខណ្ឌ១-៤។

[៣១] កំណត់ហេតុនៃការចូលខ្លួនដំបូង ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ D38 ទំព័រ២ និង៣។

("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[៣២]។ អង្គបុរេជំនុំជម្រះបានរកឃើញថា នៅពេលដែលមានធាតុផ្សំនៃអង្គហេតុដូចគ្នាបេះបិទ ទើបគេអាចអះអាងថា បទល្មើសផ្សេងបានបញ្ចូលនៅក្នុងបទចោទ ហើយប្រសិនបើធាតុផ្សំទាំងឡាយខុសគ្នា បទល្មើសផ្សេងមិនបានបញ្ចូលឡើយ[៣៣]។ នៅក្នុងសាលដីកាដដែលនេះ អង្គបុរេជំនុំជម្រះបានរកឃើញថា ជាឧទាហរណ៍ បទល្មើសក្រោមច្បាប់ជាតិរួមមានធាតុផ្សំខុសពីបទល្មើសក្រោមច្បាប់អន្តរជាតិ[៣៤]។ អង្គបុរេជំនុំជម្រះក៏បានរកឃើញផងដែរថា យោងតាមបទដ្ឋានអន្តរជាតិ ជនត្រូវចោទត្រូវតែទទួលការជូនដំណឹងអំពីបទចោទទាំងអស់ ឬបទចោទនីមួយៗដោយឡែកពីគ្នា ដែលដាក់បន្ទុកលើខ្លួន ឱ្យបានត្រឹមត្រូវ "ត្រឹមកម្រិតមួយដែលអាចឱ្យជនទាំងនេះអនុវត្តនូវសិទ្ធិទាំងឡាយដែលផ្តល់ជូនខ្លួននៅក្នុងអំឡុងពេលស៊ើបអង្កេត ដែលក្នុងនោះរួមទាំងសិទ្ធិស្នើសុំបំពេញកិច្ចស៊ើបសួរ ស្របតាមវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុង"[៣៥]។

២៧. អង្គបុរេជំនុំជម្រះសង្កេតឃើញបន្ថែមទៀតថា យោងតាមបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីជនត្រូវចោទបានតវ៉ាអំពីសេចក្តីសន្និដ្ឋាននៅក្នុងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះលក្ខខណ្ឌនៃវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង ដោយឈរលើមូលដ្ឋាននៃការចោទប្រកាន់ថា "មានកំហុសនៅក្នុងការស៊ើបអង្កេត"។ ដូចដែលសហព្រះរាជអាជ្ញាបានចង្អុលបញ្ជាក់នៅក្នុងចម្លើយតបរបស់ខ្លួន អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា ការព្រួយបារម្ភរបស់សហមេធាវីការពារក្តីគឺផ្អែកលើការចោទប្រកាន់ដែលមិនទាន់បានរកឃើញនៅឡើយ ហើយសហមេធាវីការពារក្តីមិនបានបង្ហាញឱ្យបានជាក់លាក់ថា សម្ភារៈដោះបន្ទុកបាត់ចេញពីក្នុងសំណុំរឿង ឬថាភស្តុតាងអ្វីខ្លះដែលសហចៅក្រមស៊ើបអង្កេតបានមើលរំលង ដែលអាចឱ្យអង្គបុរេជំនុំជម្រះយកមកពិចារណាឡើងវិញ។

[៣២] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

[៣៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៨៥ និង៨៨។

[៣៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ៦០-៨៨។

[៣៥] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ១៣៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

២៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា យោងតាមដីកាសម្រេចបន្តថិរវេលា សហចៅក្រមស៊ើបអង្កេតបានធ្វើការពិនិត្យមើលភស្តុតាង ដែលមាននៅក្នុងសំណុំរឿងឡើងវិញ ទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ដោយបានពិចារណាលើសម្ភារៈដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង ហើយបានសន្និដ្ឋានថា មូលហេតុដែលត្រូវបានរកឃើញ នៅតែមានអត្ថិភាព[៣៦]។

២៩. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានផ្តល់សំអាងហេតុគ្រប់គ្រាន់នៅពេលធ្វើការសន្និដ្ឋាន។ ហេតុដូច្នេះហើយ សហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវ នៅពេលសន្និដ្ឋានថា "មូលហេតុដែលត្រូវបានរកឃើញ" នៅតែមានអត្ថិភាព។

៣០. នៅពេលពិនិត្យពិចារណាលើសំណុំរឿងឡើងវិញ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា ខ្លួនបានរកឃើញមានចម្លើយ និងឯកសារថ្មីៗ នៅក្នុងសំណុំរឿង ដែលមានលក្ខណៈជាភស្តុតាងដោះបន្ទុក[៣៧] និងភស្តុតាងដាក់បន្ទុក[៣៨]។ ក្រោយពីធ្វើការពិនិត្យមើលភស្តុតាងទាំងអស់ អង្គបុរេជំនុំជម្រះមិនបានរកឃើញថា នៅក្នុងដំណាក់កាលនេះ ភស្តុតាងដោះបន្ទុកថ្មីៗនឹងមានទម្ងន់ជាងការសន្និដ្ឋានដែលថា មានហេតុផលដែលត្រូវបានរកឃើញនោះឡើយ។

៣១. អង្គបុរេជំនុំជម្រះយល់ឃើញថា វាមិនត្រឹមតែមាន "មូលហេតុដែលត្រូវបានរកឃើញ" ដែលនឹងធ្វើឱ្យអ្នកសង្កេតការណ៍អព្យាក្រឹត្យជឿថា ជនត្រូវចោទអាចធ្លាប់បានប្រព្រឹត្ត ឬអាចត្រូវទទួលខុស

[៣៦] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ១៥-១៨។

[៣៧] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាឡុត បាន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ (ដាក់នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩) ឯកសារ D233/2 ទំព័រ៣។

[៣៨] [redacted]

ត្រូវលើឧក្រិដ្ឋកម្មទាំងឡាយ ដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដូចដែលសហចៅក្រមស៊ើបអង្កេតបានអះអាង នៅក្នុងដីកាសម្រេចបន្តថិរវេលាប៉ុណ្ណោះទេ វាថែមទាំងមានភស្តុតាងបន្ថែមជាមូលដ្ឋានគាំទ្រផងដែរដល់ "មូលហេតុដែលត្រូវបានរកឃើញ" នៅក្នុងដំណាក់កាលនេះ។

៣២. ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌទីមួយដែលបង្គាប់ឱ្យមានការឃុំខ្លួនបណ្ដោះអាសន្ន ដូចបានចែងនៅក្នុងវិធាន ៦៣(៣)(ក) នៅតែបានបំពេញ។

**ខ. ការពិចារណាលើមូលដ្ឋានដែលធ្វើឱ្យការឃុំខ្លួនបណ្ដោះអាសន្នជាវិធានការដ៏ចាំបាច់មួយ(វិធាន ៦៣(៣)(ខ)នៃវិធានផ្ទៃក្នុង)៖**

៣៣. យោងតាមដីកាសម្រេចបន្តថិរវេលា សហចៅក្រមស៊ើបអង្កេតបានយោងលើការរកឃើញរបស់អង្គបុរេជំនុំជម្រះនៅក្នុងសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ **អៀង សារី** ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី២៦ ខែមិថុនាឆ្នាំ២០០៦[៣៩] ហើយសហចៅក្រមស៊ើបអង្កេតបានពិចារណាថា តើលក្ខខណ្ឌដូចមានចែងនៅក្នុងវិធាន៦៣(៣)(ខ) នៅតែបានបំពេញដែរឬយ៉ាងណា។ យោងតាមដីកាសម្រេចបន្តថិរវេលា សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ដោយសារតែមិនមានកាលៈទេសៈប្រែប្រួល ការឃុំខ្លួននៅតែជាវិធានការចាំបាច់ក្នុងការធានាវត្តមានរបស់ជនត្រូវចោទនៅក្នុងកិច្ចដំណើរការនីតិវិធី ដើម្បីការពារសន្តិសុខរបស់ជនត្រូវចោទ និងការរក្សាសណ្ដាប់ធ្នាប់សាធារណៈ[៤០]។

៣៤. អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលអនុវត្តបទដ្ឋាននេះ សហចៅក្រមស៊ើបអង្កេតបានបំពេញកិច្ចរបស់ខ្លួនបានត្រឹមត្រូវ។

***<u>ភាពចាំបាច់ដើម្បីធានានូវវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី (វិធាន៦៣(៣)(ខ)(iii) នៃវិធានផ្ទៃក្នុង)៖</u>***

[៣៩] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តការឃុំខ្លួន។

[៤០] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌ២០-២៧។

៣៥. សហមេធាវីការពារក្តីបានអះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតមានកំហុស នៅពេលខកខានមិនបានពិចារណាឱ្យបានពេញលេញលើស្ថានភាពបច្ចុប្បន្នដែលជនត្រូវចោទមានអាយុ៨៤ឆ្នាំ។ ជនត្រូវចោទមានបញ្ហាសុខភាពធ្ងន់ធ្ងរ ដែលកម្រិតលើការបំលាស់ទីតាំងរបស់ខ្លួន ហើយគេដឹងយ៉ាងច្បាស់ថា ជនត្រូវចោទទំនងជាមិនអាចរត់គេចខ្លួន ដោយមិនមានគេដឹងនោះឡើយ"។ សហមេធាវីការពារក្តីបានសន្និដ្ឋានបន្ថែមទៀតថា អ.វ.ត.ក ខុសពីសាលាក្តីអន្តរជាតិដទៃទៀត ដោយសារ អ.វ.ត.ក មាននគរបាលយុត្តិធម៌ និងអាជ្ញាធរដែលចេញដីកាបង្គាប់ឱ្យនាំខ្លួន[៤១]។ តាមការលើកឡើងបន្ថែមរបស់សហមេធាវីការពារក្តីនៅក្នុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍ វាមានន័យថា វាងាយស្រួលសម្រាប់ អ.វ.ត.ក ក្នុងការតាមដាន ឬចាប់ខ្លួនជនត្រូវចោទ ប្រសិនបើមានការដោះលែងឱ្យមានសេរីភាព[៤២]។

៣៦. នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានអះអាងថា ករណីដែលជនត្រូវចោទជាបុគ្គលដែលល្បីឈ្មោះមួយរូបបង្ហាញថា គាត់មិនទំនងជាមនុស្សគ្មានទំនាក់ទំនង ដែលអាចជួយគាត់ក្នុងការរត់គេចខ្លួននោះទេ។ សហព្រះរាជអាជ្ញាបន្ថែមទៀតថា អ.វ.ត.ក មាននគរបាលយុត្តិធម៌ និងអាជ្ញាធរដែលចេញដីកាបង្គាប់ឱ្យនាំខ្លួន គឺមិនមានការជាប់ពាក់ព័ន្ធទេនៅក្នុងពេលបច្ចុប្បន្ន ហើយវាពាក់ព័ន្ធតែក្នុងករណីជនត្រូវចោទបានរត់គេចខ្លួនហើយតែប៉ុណ្ណោះ។ ក្នុងករណីនេះ វាមិនអាចធ្វើអ្វីបានដើម្បីធានាអះអាងសារជាថ្មីចំពោះតុលាការនេះថា ហានិភ័យនៃការរត់គេចខ្លួនមិនអាចមានលទ្ធភាពធ្វើទៅរួចនោះឡើយ។ សហព្រះរាជអាជ្ញាបានចង្អុលបញ្ជាក់ទៀតថា សហមេធាវីការពារក្តីមិនបានផ្តល់ភស្តុតាងថ្មីដើម្បីឱ្យអង្គបុរេជំនុំជម្រះជឿជាក់រហូតដល់ថ្នាក់អាចបដិសេធចោលការរកឃើញរបស់ខ្លួន កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៨ នោះទេ[៤៣]។

៣៧. ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានស្នើឡើង នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ថា អង្គបុរេជំនុំជម្រះគួរអនុវត្តតាមយុត្តិសាស្ត្ររបស់ អ.វ.ត.ក និងគួរយល់ឃើញថា "យោងតាមវិធាន

---

[៤១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៦-១៧។

[៤២] ប្រតិចារឹកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ទំព័រ២៨ និង៤១។

[៤៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១១-១២។

២១(២) នៃវិធានផ្ទៃក្នុង ការឃុំខ្លួន[ជនជាប់ចោទ] គឺត្រឹមត្រូវតាមលក្ខខណ្ឌនៃកិច្ចដំណើរការនីតិវិធី [..] ជាពិសេសតម្រូវការក្នុងការធានាវត្តមានរបស់ជនជាប់ចោទ និងមានលក្ខណៈសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ"[៤៤]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៃទៀត បានបន្ថែមនៅក្នុងសេចក្តីសង្កេតរបស់ខ្លួនថា អង្គបុរេជំនុំជម្រះគួរតែពិចារណាផងដែរលើ "ឋានៈជាមេដឹកនាំជាន់ខ្ពស់ ទំនាក់ទំនងនានា និងទោសដែលជនត្រូវចោទត្រូវទទួលរង"[៤៥]។

៣៨. ចំពោះទឡ្ហីករណ៍របស់សហមេធាវីការពារក្តីថា អាយុ និងសុខភាពរបស់ជនត្រូវចោទកម្រិតលើការផ្លាស់ប្តូរទីតាំងរបស់ជននេះ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ខ្លួនបានសម្រេចលើទឡ្ហីករណ៍ដូចគ្នានេះនៅក្នុងសាលដីការបស់ខ្លួនលើកមុន លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន[៤៦] ហើយសហមេធាវីការពារក្តីមិនបានផ្តល់ភស្តុតាងណាមួយដែលបង្ហាញថា នៅក្នុងដំណាក់កាលនេះ ជនត្រូវចោទនឹងមិនមានលទ្ធភាពរត់គេចខ្លួនចេញពីប្រទេសនេះទោះបីតាមរយៈការប្រើប្រាស់មធ្យោបាយធ្វើដំណើរណាមួយក៏ដោយ។

៣៩. ចំពោះអំណាចរបស់អង្គជំនុំជម្រះទាំងអស់របស់ អ.វ.ត.ក ក្នុងការចេញដីកាបង្គាប់ឱ្យនាំខ្លួនវិញ អង្គបុរេជំនុំជម្រះយល់ឃើញថា អ.វ.ត.ក មាននគរបាលយុត្តិធម៌ និងអាជ្ញាធរដែលចេញដីកាបង្គាប់ឱ្យនាំខ្លួន គឺមិនអាចធ្វើអ្វីបានដើម្បីធានាអះអាងសារជាថ្មីចំពោះតុលាការនេះថា ហានិភ័យនៃការរត់គេចខ្លួនមិនអាចមានលទ្ធភាពធ្វើទៅរួចនោះឡើយ។ អង្គបុរេជំនុំជម្រះយល់ឃើញទៀតថា ក្នុងពេលដែលហានិភ័យកំពុងត្រូវបានជជែកវែកញែក បញ្ហានេះមិនត្រូវផ្តល់ប្រយោជន៍នៃវិមតិសង្ស័យដល់ជនត្រូវចោទឡើយ ដោយសារបញ្ហានេះជាការពិនិត្យទៅលើលទ្ធភាពដើម្បីធានាវត្តមានរបស់ជនត្រូវចោទ នៅក្នុងករណីដែលជននេះរត់គេចខ្លួន ហើយមិនចូលខ្លួនទៅតុលាការ។ ដូច្នេះទឡ្ហីករណ៍ដែលបានលើកឡើងនេះនឹងមិនយកមកធ្វើការពិភាក្សាបន្ថែមទៀតឡើយ។

---

[៤៤] ចម្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ២៣-២៤។

[៤៥] សេចក្តីអង្កេតរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ២០-២១។

[៤៦] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តការឃុំខ្លួន កថាខណ្ឌ២៨។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

៤០. អង្គបុរេជំនុំជម្រះមិនត្រូវពិចារណាលើទឡ្ហីករណ៍របស់សហមេធាវីការពារក្តីដែលបានលើកឡើងថា ជនត្រូវចោទមានឈ្មោះល្បី ហើយទំនងជាមិនអាចរត់គេចខ្លួន ដោយមិនមានគេដឹងនោះឡើយ ពីព្រោះបញ្ហានៅក្នុងកិច្ចដំណើរការនីតិវិធីនេះមិនមែន ដើម្បីវាយតម្លៃថាតើជនត្រូវចោទអាចរត់គេចខ្លួន ដោយមានគេដឹង ឬ មិនមានគេដឹងនោះទេ។ ប៉ុន្តែ អង្គជំនុំជម្រះត្រូវពិចារណាថាតើជននេះអាចរត់គេចខ្លួនដែរឬទេ។

៤១. ដូចដែលសហព្រះរាជអាជ្ញាបានចង្អុលបញ្ជាក់ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញទៀតថា សហមេធាវីការពារក្តីមិនបានផ្តល់ភស្តុតាងថ្មី ដើម្បីឱ្យអង្គបុរេជំនុំជម្រះជឿជាក់រហូតដល់ថ្នាក់អាចបដិសេធចោលការរកឃើញរបស់ខ្លួនកាលពីលើកមុនលើបញ្ហានេះ ដែលជាមូលដ្ឋាននៃដីកាសម្រេចដែលត្រូវបានគេប្តឹងឧទ្ធរណ៍។

៤២. នៅពេលពិចារណាលើភាពធ្ងន់ធ្ងរនៃបទចោទ អង្គបុរេជំនុំជម្រះលើកឡើងម្តងទៀតថា ជនត្រូវចោទអាចទទួលទោសជាប់ពន្ធនាគារពីប្រាំឆ្នាំទៅមួយជីវិត ប្រសិនបើរកឃើញថាមានពិរុទ្ធភាព។ យើងមិនឃើញមានភស្តុតាងនៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្ន នាំឱ្យមានការសន្និដ្ឋានថា កាលៈទេសៈទាំងឡាយបានផ្លាស់ប្តូរទេ។ បន្ថែមលើចំនុចនេះ ភស្តុតាងថ្មីៗបានដែលបានដាក់បន្ថែមចូលទៅក្នុងសំណុំរឿង បានផ្តល់ទម្ងន់បន្ថែមលើទឡ្ហីករណ៍ ដែលគាំទ្រចំពោះទំនាក់ទំនងរវាងអំពើដែលបានចោទប្រកាន់ និងជនត្រូវចោទ ដែលជាហេតុធ្វើឱ្យវាមានសម្ពាធធ្ងន់បន្ថែមទៀតដល់ជននេះ[៤៧]។

៤៣. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា វានៅតែមានភាពចាំបាច់ក្នុងការឃុំខ្លួនជនត្រូវចោទ ដើម្បីធានាវត្តមានរបស់ជននេះនៅក្នុងកិច្ចដំណើរការនីតិវិធី។

<u>**ភាពចាំបាច់ក្នុងការការពារសន្តិសុខរបស់ជនត្រូវចោទ (វិធាន ៦៣(៣)(ខ)(iv) នៃវិធានផ្ទៃក្នុង)៖**</u>

[៤៧] សូមមើលកថាខណ្ឌ២៩ខាងលើ។

៤៤. សហមេធាវីការពារក្តីបានសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតមានកំហុសនៅពេលពិចារណាថា ការភ័យខ្លាចចំពោះការប្រើអំពើហិង្សាមកលើ ឌុច អាចត្រូវយកមកធ្វើការពិចារណា នៅពេលធ្វើការវាយតម្លៃលើសន្តិសុខរបស់ជនត្រូវចោទ ពីព្រោះជននេះមិនបានសារភាពចំពោះឧក្រិដ្ឋកម្មណាមួយនោះទេ ហើយដោយសារថា ការជំនុំជម្រះក្តីមកលើរូបគាត់មិនទាន់បានចាប់ផ្តើមនៅឡើយ នោះការផ្សព្វផ្សាយជុំវិញបទឧក្រិដ្ឋដែលបានចោទប្រកាន់ប្រឆាំងរូបគាត់ គឺមានភាពធូរស្រាលជាងទិដ្ឋភាពជុំវិញឧក្រិដ្ឋកម្មរបស់ ឌុច។ សហមេធាវីកាពារក្តីបានបន្ថែមទៀតថា លទ្ធផលនៃការជំនុំជម្រះលើ ឌុច នឹងលើកកម្ពស់លើជំនឿរបស់សាធារណៈជននៅក្នុងប្រព័ន្ធតុលាការ ដែលវាគួរតែជួយសម្រាលហានិភ័យនៃអំពើហិង្សាចំពោះជនត្រូវចោទ[៤៨]។

៤៥. នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា សហមេធាវីការពារក្តី "បានផ្តល់ជាទ្រឹស្តីក្នុងការប្រែប្រួលអារម្មណ៍នៅក្នុងសង្គមកម្ពុជា ដែលជាការប៉ាន់ស្មានយ៉ាងសុទ្ធសាធ ហើយការដាក់ទោស [ឌុច] ដែលបានរំពឹងទុក មិនអាចត្រូវបានគេចាត់ទុកថាជាការផ្លាស់ប្តូរកាលៈទេសៈមួយបានទេ ដោយហេតុថាវានៅមិនទាន់បានកើតឡើងនៅឡើយទេ"[៤៩]។

៤៦. នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា ករណី ឌុច និងជនត្រូវចោទនេះមិនដូចគ្នាទេ ប៉ុន្តែ "ទោះជាយ៉ាងណាក៏ដោយ រឿងក្តីទាំងពីរនេះអាចយកមកធ្វើការប្រៀបធៀបបាន ដោយសារជនទាំងពីរនេះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋធ្ងន់ធ្ងរស្រដៀងគ្នានៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក"។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបន្ថែមទៀតថា ជនត្រូវចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មច្រើនជាង ឌុច ពីព្រោះជនត្រូវចោទរូបនេះត្រូវបានចោទប្រកាន់ជាមេដឹកនាំជាន់ខ្ពស់មួយរូប ហើយនៅពេលដែល ឌុច បានទទួលស្គាល់នូវការទទួលខុសត្រូវរបស់ខ្លួន ហើយបានសហការជាមួយនឹងតុលាការ ជនត្រូវចោទរូបនេះមិនបានធ្វើដូច្នេះទេ[៥០]។ នៅក្នុងសេចក្តីសង្កេតរបស់ខ្លួន សហមេធាវីតំណាង

[៤៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៨-១៩។

[៤៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៣-១៤។

[៥០] ចម្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ២៤។

00505924



ដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតបានបន្ថែមទៀតថា ជនត្រូវចោទអាចទទួលរងនូវការសងសឹកពីជនរងគ្រោះ ប្រសិនបើដោះលែងឱ្យមានសេរីភាព[៥១]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបន្ថែមទៀតនៅក្នុងសវនាការនាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ថា "តួនាទីដ៏ខ្ពស់ និងមានអំណាចរបស់ជនត្រូវចោទក្នុង[របប]កម្ពុជាប្រជាធិបតេយ្យ បានធ្វើឱ្យប្រជាពលរដ្ឋផ្តោតការចាប់អារម្មណ៍កាន់តែខ្លាំងទៅៗ។ [ការខកខានរបស់គាត់ក្នុងការសហការជាមួយតុលាការ] មិនមែនមានន័យថាជាហេតុផលដែលនាំមកនូវភាពស្ងប់ស្ងាត់ និងការផ្សះផ្សានោះទេ ប៉ុន្តែវាអាចកាន់តែជាការបង្កើននូវការឈឺចាប់ខ្លាំងជាងមុនដល់ជនរងគ្រោះទូទាំងប្រទេស"[៥២]។

៤៧. អង្គបុរេជំនុំជម្រះសង្កេតឃើញថា យោងតាមដីកាសម្រេចបន្តថិរវេលា សហចៅក្រមស៊ើបអង្កេតបានពិចារណាថាតើលក្ខខណ្ឌដូចមានចែងនៅក្នុងវិធាន៦៣(៣)(ខ)(iv)នៃវិធានផ្ទៃក្នុង ដែលចាំបាច់ក្នុងការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបានបំពេញដែរឬទេ នៅពេលពិចារណាលើការរកឃើញរបស់អង្គបុរេជំនុំជម្រះ នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។ សហចៅក្រមស៊ើបអង្កេតមិនបានរកឃើញថាមានការផ្លាស់ប្តូរកាលៈទេសៈឡើយ ហើយបានសន្និដ្ឋានថា ការឃុំខ្លួនបណ្តោះអាសន្ននៅតែជាវិធានការចាំបាច់ក្នុងការការពារសន្តិសុខដល់ជនត្រូវចោទ។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញទៀតថា សហមេធាវីការពារក្តីមិនបានដាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះនូវទឡ្ហីករណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយផ្ទុយពីនេះឡើយ។ ទោះបីជាអង្គបុរេជំនុំជម្រះ ពិនិត្យបន្ថែមលើសំណុំរឿងក៏ដោយ ក៏ខ្លួនមិនមានការយល់ខុសពីសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតនោះដែរ។

៤៨. ចំពោះការលើកឡើងរបស់សហមេធាវីការពារក្តីថា សហចៅក្រមស៊ើបអង្កេតមានកំហុសនៅពេលយកការភ័យខ្លាចថា មានអំពើហិង្សាមកលើ ឌុច មកពិចារណា ពីព្រោះជនត្រូវចោទមិនបានសារភាពចំពោះឧក្រិដ្ឋកម្មណាមួយនោះទេ ហើយដោយសារថា ការជំនុំជម្រះក្តីមកលើជននេះមិន

[៥១] សេចក្តីអង្កេតរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ២៤។

[៥២] ប្រតិចារឹកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ទំព័រ៧៥។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ទាន់បានចាប់ផ្តើមនៅឡើយ នោះការផ្សព្វផ្សាយជុំវិញបទឧក្រិដ្ឋដែលបានចោទប្រកាន់ប្រឆាំងរូបគាត់ គឺមានភាពធូរស្រាលជាងទិដ្ឋភាពជុំវិញឧក្រិដ្ឋកម្មរបស់ ឌុច។ ចំពោះករណីនេះ អង្គបុរេជំនុំជម្រះសង្កេតឃើញដូចនឹងការចង្អុលបង្ហាញរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងចម្លើយតបដែរថា បើទោះជាមានគោលការណ៍សច្ចធារណ៍នៃនិរទោសក៏ដោយ បទចោទទាំងឡាយដែលដាក់បន្ទុកលើជនត្រូវចោទមានលក្ខណៈធ្ងន់ធ្ងរជាងបទចោទទាំងឡាយដែលចោទប្រកាន់លើ ឌុច។ ខណៈពេលដែល ឌុច អាចត្រូវបានគេយល់ឃើញថាបានសហការជាមួយនឹងតុលាការ ជនត្រូវចោទហាក់ដូចជាបានអនុវត្តនូវសិទ្ធិទាំងឡាយរបស់ខ្លួន។ អង្គបុរេជំនុំជម្រះនឹងមិនទទួលយកការសន្និដ្ឋានផ្ទុយពីនេះ ដែលដើមបណ្តឹងរដ្ឋប្បវេណីព្យាយាមធ្វើឡើង ដោយផ្អែកលើការអនុវត្តសិទ្ធិទាំងនេះឡើយ។

៤៩. ចំពោះសេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារក្តីថា លទ្ធផលនៃការជំនុំជម្រះលើ ឌុច នឹងលើកកម្ពស់លើជំនឿរបស់សាធារណៈជននៅក្នុងប្រព័ន្ធតុលាការ ដែលវាគួរតែជួយសម្រាលហានិភ័យនៃអំពើហិង្សាចំពោះជនត្រូវចោទ អង្គបុរេជំនុំជម្រះយល់ឃើញដូចសហព្រះរាជអាជ្ញាដែរថា ការដាក់ទោស ឌុច ដែលបានរំពឹងទុកមិនអាចត្រូវបានគេចាត់ទុកថាជាការផ្លាស់ប្តូរកាលៈទេសៈមួយបានទេ ដោយហេតុថាវានៅមិនទាន់បានកើតឡើងនៅឡើយទេ។

៥០. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា ការឃុំខ្លួនបណ្តោះអាសន្ននៅតែជាវិធានការចាំបាច់ក្នុងការការពារសុវត្ថិភាពជនត្រូវចោទ។

**ភាពចាំបាច់ក្នុងការធានាសណ្តាប់ធ្នាប់សាធារណៈ (វិធាន ៦៣(៣)(ខ)(v) នៃវិធានផ្ទៃក្នុង)៖**

៥១. សហមេធាវីការពារក្តីបានសន្និដ្ឋានថា ការចាប់អារម្មណ៍របស់សាធារណៈជនលើកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក មិនអាចប្រើប្រាស់ជាមូលដ្ឋានក្នុងការចេញដីកាសម្រេចបន្តថិរវេលាឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នឡើយ។ សហមេធាវីការពារក្តីបានផ្តល់ទឡ្ហីករណ៍បន្តទៀតថា សង្គមកម្ពុជាមិនទទួលរងការគម្រាមកំហែងដោយសារការប្រកាសថា ការជំនុំជម្រះថ្មីៗទៀតអាចនឹងចាប់ផ្តើមឡើយ ហើយ“មិនមានអ្នកណាម្នាក់យកចិត្តទុកដាក់អំពីការគំរាមកំហែងចំពោះអស្ថេរភាព

យ៉ាងខ្លាំងក្លាទេ”។ សហមេធាវីការពារក្តីបានយោងលើអត្ថបទចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ នៅក្នុង International Justice Tribune ដើម្បីយកមកគាំទ្រលើទឡ្ហីករណ៍របស់ខ្លួន[៥៣]។

៥២. នៅពេលឆ្លើយតប សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា “វាមិនច្បាស់លាស់ទេថា តើសេចក្តីសំអាងដែលថាពុំមានការខូចដល់សណ្តាប់ធ្នាប់សាធារណៈ នៅពេលមានការប្រកាសថានឹងមានការស៊ើបសួរទៅលើជនសង្ស័យចំនួនប្រាំរូបបន្ថែមទៀតនោះ នឹងមានទម្ងន់អ្វីខ្លះទៅលើឥទ្ធិពលជាសក្តានុពលទៅលើសណ្តាប់ធ្នាប់សាធារណៈ ដែលថាការដោះលែងជនត្រូវចោទ ត្រូវបានគេដឹងឮយ៉ាងទូលំទូលាយ ដូចដែលដើមបណ្តឹងឧទ្ធរណ៍ និងអ្នកចូលរួមជាមួយ ឌុច អាចនឹងមានគេដឹងឮបាន”។ សហព្រះរាជអាជ្ញាបានបន្ថែមទៀតថា សហមេធាវីការពារក្តីជនត្រូវចោទ “ចាប់តាំងពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩ ពុំបានផ្តល់នូវភស្តុតាងថ្មីណាមួយ ដែលអាចធ្វើឱ្យអង្គបុរេជំនុំជម្រះជឿជាក់ដើម្បីកែប្រែការយល់ឃើញរបស់ខ្លួនកន្លងមកនោះទេ”[៥៤]។

៥៣. ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានសន្និដ្ឋានថា “ការដាក់ឱ្យ[ជនត្រូវចោទ]មានសេរីភាពនៅក្រៅឃុំអាចនាំឱ្យមានការពិបាកយល់ពីសំណាក់ប្រជាជន ហើយហានិភ័យសំខាន់ដែលសម្តែងចេញមករបស់អ្នកទាំងនោះអាចជាការហិង្សា”[៥៥]។

៥៤. អង្គបុរេជំនុំជម្រះនឹងមិនពិភាក្សាលើទឡ្ហីករណ៍ ដែលសហមេធាវីការពារក្តីបានលើកឡើងជំទាស់នឹងការរកឃើញមុនៗរបស់អង្គបុរេជំនុំជម្រះ ដោយសារមិនមានទឡ្ហីករណ៍អ្វីថ្មីបានលើកឡើងនៅពេលពិចារណាលើមូលដ្ឋាននៃការឃុំខ្លួនបណ្តោះអាសន្នមួយនេះ។ អង្គបុរេជំនុំជម្រះយល់ឃើញថាការរកឃើញមុនៗមិនមែនជាកម្មវត្ថុនៃការពិភាក្សាទៀតឡើយ លើកលែងតែលក្ខខណ្ឌទាមទារឱ្យ

[៥៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២១-២២។

[៥៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៥។

[៥៥] សេចក្តីសង្កេតរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ២៦។

ពិចារណាឡើងវិញលើសេចក្តីសម្រេចបានបំពេញ[៥៦]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះនឹងមិនធ្វើការពិភាក្សាលើទឡ្ហីករណ៍ ដែលបានលើកឡើងទាំងនេះនោះទេ។

៥៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ដូចការលើកឡើងរបស់សហព្រះរាជអាជ្ញាដែរថា វាមិនមានភាពច្បាស់លាស់ថា តើផលប៉ះពាល់ចំពោះសណ្តាប់ធ្នាប់សាធារណៈ ដោយសារការប្រកាសអំពីការស៊ើបអង្កេតបន្ថែមទៀត មានភាពជាប់ពាក់ព័ន្ធយ៉ាងដូចម្តេចទៅនឹងផលប៉ះពាល់ដែលគេគិតថានឹងមានចំពោះសណ្តាប់ធ្នាប់សាធារណៈ ក្នុងករណីដែលដោះលែងជនត្រូវចោទឱ្យមានសេរីភាពនោះ។ អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា អត្ថបទចេញផ្សាយនៅក្នុង The International Justice Tribune ដែលសហមេធាវីការពារក្តីបានយកមកប្រើប្រាស់នៅក្នុងបណ្តឹងឧទ្ធរណ៍នោះ ជាការរៀបរាប់តាមការទាយស្មាននូវអ្វី ដែលអាចកើតឡើងនៅ អ.វ.ត.ក ហើយវាជាសេចក្តីប្រកាសមួយគ្មានមូលដ្ឋាន ដោយសារគេមិនមានការពិចារណាលើអស្ថេរភាពឱ្យបានជិតដល់។

៥៦. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតបានអះអាងបញ្ជាក់នៅក្នុងដីកាសម្រេចថា ចាប់តាំងពីអង្គបុរេជំនុំជម្រះ បានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ខ្លួនមិនបានរកឃើញការផ្លាស់ប្តូរកាលៈទេសៈណាមួយដែលនាំឱ្យខ្លួនយល់ឃើញថា ការបន្តការឃុំខ្លួនមិនមានភាពចាំបាច់នោះទេ។ សហមេធាវីការពារក្តីមិនបានដាក់ជូននៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះនូវទឡ្ហីករណ៍ ឬ ការផ្លាស់ប្តូរកាលៈទេសៈណាមួយ ដែលបង្ហាញផ្ទុយពីនេះទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថា យោងតាមដីកាសម្រេចបន្តថិរវេលាត្រង់ផ្នែកនេះ សហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវនៅពេលរកឃើញថា ការឃុំខ្លួននៅតែមានភាពចាំបាច់ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ។

**គ. ការយកចិត្តទុកដាក់របស់សហចៅក្រមស៊ើបអង្កេត៖**

---

[៥៦] សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មី អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង ឯកសារ C22/I/68 ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ២៥។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00505928



៥៧. យោងតាមដីកាសម្រេចបន្តថិរវេលា សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ថា "ការកន្លងទៅនៃពេលវេលា ចាប់តាំងពីពេលឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន គឺមានការជាប់ពាក់ព័ន្ធនឹងការសម្រេចអំពីនីត្យានុកូលភាពក្នុងការបន្តឃុំខ្លួនជននេះបណ្ដោះអាសន្នបន្តទៀត"[៥៧]។ សហចៅក្រមស៊ើបអង្កេត បានចង្អុលបញ្ជាក់ថា វិសាលភាពនៃការស៊ើបអង្កេតដូចដែលបានទាមទារនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើជនត្រូវចោទនៅក្នុងដីកានោះ ទាមទារឱ្យមានកិច្ចស៊ើបសួរដែលមានទំហំធំធេង។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងបន្ថែមនៅក្នុងដីកាសម្រេចបន្តថិរវេលា អំពីកិច្ចស៊ើបសួរដែលបានបំពេញចាប់តាំងពីថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩ ដែលក្នុងនោះរួមបញ្ចូលកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី និងឯកសារផ្សេងទៀត ដែលបានដាក់បន្ថែមចូលទៅក្នុងសំណុំរឿងតាមសំណើរបស់ភាគី ឬតាមគំនិតផ្ដួចផ្ដើមរបស់សហចៅក្រមស៊ើបអង្កេត[៥៨]។

៥៨. សហមេធាវីការពារក្ដីមិនបានបង្ហាញទឡ្ហីករណ៍ទាំងឡាយ នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ដើម្បីតវ៉ាលើការយកចិត្តទុកដាក់ដ៏ត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេតឡើយ។ នៅក្នុងពេលសវនាការថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានសន្និដ្ឋានលើបញ្ហានេះដោយប្រយោល ដោយនិយាយថា ចម្លើយសាក្សីចំនួន៨០០ បានទទួលបាន ហើយមានលិខិតចាត់ឱ្យសួរជំនួសចំនួន៥០០ លិខិត នៅក្នុងអំឡុងពេលស៊ើបអង្កេតទាំងមូល[៥៩]។ យោងតាមចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនបានផ្ដល់ជូនទឡ្ហីករណ៍ទាំងឡាយចំពោះបញ្ហានេះឡើយ។

៥៩. អង្គបុរេជំនុំជម្រះយល់ឃើញថា ភាពសមស្របនៃរយៈពេលឃុំខ្លួន និងការយកចិត្តទុកដាក់របស់សហចៅក្រមស៊ើបអង្កេតនៅក្នុងការបំពេញកិច្ចស៊ើបសួរ គឺជាកត្តាដែលត្រូវយកមកធ្វើការពិចារណានៅពេលអនុវត្តអំណាចឆន្ទានុសិទ្ធិក្នុងការបន្តការឃុំខ្លួនបណ្ដោះអាសន្ន។ អង្គបុរេជំនុំជម្រះបាន

---

[៥៧] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌ២៨។

[៥៨] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌ២៩-៣០។

[៥៩] ប្រតិចារឹកនៃសវនាការលើបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ទំព័រ៥២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

យោងលើរយៈពេល ចាប់តាំងពីថ្ងៃសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួននៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩ រហូតមកដល់ថ្ងៃសវនាការនាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០។

៦០. អង្គបុរេជំនុំជម្រះយល់ឃើញថា មានភស្តុតាងបន្ថែមគ្រប់គ្រាន់នៅក្នុងសំណុំរឿងបង្ហាញថា ការស៊ើបអង្កេតបានវិវត្តទៅមុខយ៉ាងលឿន ក្នុងអំឡុងពេលនៃការពិចារណានេះ។ សហចៅក្រមស៊ើបអង្កេតបានផ្តល់សំអាងហេតុគ្រប់គ្រាន់នៅក្នុងដីកាសម្រេចបន្តថិរវេលា ដើម្បីជាការគាំទ្រដល់ការរកឃើញនេះ[៦០]។

៦១. អង្គបុរេជំនុំជម្រះយល់ឃើញថា ភាពធ្ងន់ធ្ងរ និងលក្ខណៈនៃឧក្រិដ្ឋកម្ម ដែលចោទប្រកាន់លើជនត្រូវចោទទាមទារឱ្យមានកិច្ចស៊ើបសួរមួយដែលមានទំហំធំធេង ដែលបានបំពេញរួចហើយ។ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលពិចារណាលើវិសាលភាព និងដំណាក់កាលស៊ើបអង្កេតនៅពេលបច្ចុប្បន្ននេះ សហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងសមហេតុផល នៅពេលចេញដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួន។

**ឃ. សំណើសុំឃុំខ្លួននៅក្នុងផ្ទះ និងការឃុំខ្លួននៅក្នុងមន្ទីរពេទ្យ៖**

៦២. សហមេធាវីការពារក្តីបានសន្និដ្ឋាននៅក្នុងបណ្តឹងឧទ្ធរណ៍ថា សហចៅក្រមស៊ើបអង្កេតបានរំលោភទៅលើឆន្ទានុសិទ្ធិ ដោយបានខកខានមិនបានពិចារណាពីជម្រើសឃុំឃាំងខ្លួន ដែលមានលក្ខណៈធូរស្រាលជាង មុននឹងសម្រេចសេចក្តីពន្យារការឃុំខ្លួន ជនត្រូវចោទ[៦១]។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ចំពោះករណីនេះ សហមេធាវីការពារក្តីមិនបានបង្ហាញនូវកាលៈទេសៈថ្មីៗ នៅក្នុងសំណើរបស់ខ្លួនចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តការឃុំខ្លួនបណ្តោះអាសន្ន។ អង្គបុរេជំនុំជម្រះសង្កេតឃើញទៀតថា សហចៅក្រមស៊ើបអង្កេតបានរកឃើញនៅក្នុងដីកាសម្រេចបន្តថិរវេលាថា លក្ខខណ្ឌនៅក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុងបានបំពេញ ហេតុដូច្នេះ

[៦០] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ៣០ និងជើងទំព័រដែលទាក់ទង។

[៦១] បណ្តឹងឧទ្ធរណ៍ ផ្នែកIII/B កថាខណ្ឌ២៣-២៦។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE * E.C.C.C * C.E.T.C *

សហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន បានត្រឹមត្រូវនៅពេលពន្យារការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន។

៦៣. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ទោះបីនៅក្នុងបណ្តឹងឧទ្ធរណ៍ដែលទាមទារឱ្យមានការដោះលែង សហមេធាវីការពារក្តីជនត្រូវចោទបានស្នើសុំ“ការបញ្ចប់នូវការឃុំខ្លួនបណ្តោះអាសន្ន” ក៏ដោយ នៅក្នុងថ្ងៃសវនាការនាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ លើបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីបានបញ្ជាក់បំភ្លឺថា ខ្លួនមិនស្នើសុំឱ្យមានការដោះលែងឱ្យមានសេរីភាពជាបណ្តោះអាសន្ននោះឡើយ ហើយខ្លួនស្នើសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាលើការបង្គាប់ឱ្យមានការឃុំខ្លួននៅក្នុងផ្ទះ ឬការឃុំខ្លួននៅក្នុងមន្ទីរពេទ្យ ជាជាងការឃុំខ្លួននៅក្នុងមន្ទីរឃុំខ្លួនរបស់ អ.វ.ត.ក[៦២]។

៦៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ខ្លួនបានសម្រេចនៅក្នុងសំណើដូចគ្នានេះដែរនៅក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ ដោយក្នុងនោះបានសម្រេចថា “លក្ខខណ្ឌនៃវិធាន៦៣(៣)(ខ) នៅតែត្រូវបានបំពេញ។ គ្រាន់តែមានលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌផ្សេងទៀត គឺគ្រប់គ្រាន់ដើម្បីធ្វើឱ្យមានយុត្តិកម្មក្នុងការបន្តឃុំខ្លួនជនត្រូវចោទ។ លក្ខខណ្ឌដែលស្នើឡើងដោយជនត្រូវចោទ មិនសមស្របតាមភាពចាំបាច់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទនោះទេ”[៦៣]។

៦៥. ដោយសារតែសំណើសុំដាក់ឃុំខ្លួននៅក្នុងផ្ទះមិនមានការលើកឡើងនូវភស្តុតាងថ្មីបន្ថែម ហើយមិនមានការបង្ហាញអំពីការផ្លាស់ប្តូរកាលៈទេសៈនោះ អង្គបុរេជំនុំជម្រះបដិសេធសំណើនេះចោល ដោយមិនចាំបាច់បង្ហាញសំអាងហេតុបន្ថែមឡើយ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន៖**

១. ទទួលយកបណ្តឹងឧទ្ធរណ៍នេះតាមទម្រង់។

---

[៦២] ប្រតិចារឹកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ទំព័រ២៥។

[៦៣] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តការឃុំខ្លួន កថាខណ្ឌ៤៨។

00505931

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៣២)

លេខ/C22/9/14

២.តម្កល់ដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ដោយមានមូលហេតុដូចបានលើកឡើងនៅក្នុងកថាខណ្ឌ៣០-៣២ នៃសាលដីកានេះ ដែលជាមូលហេតុបន្ថែមលើមូលហេតុរបស់សហចៅក្រមស៊ើបអង្កេត។

៣. បដិសេធសំណើកែប្រែលក្ខខណ្ឌនៃការឃុំខ្លួន។

៤. បដិសេធបណ្តឹងឧទ្ធរណ៍នេះចោលទុកជាឥតបានការ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា ។

សាលដីកានេះ **ប្រកាសជាសាធារណៈ** ដោយអង្គបុរេជំនុំជម្រះ ចំពោះមុខជនត្រូវចោទ និងសហមេធាវីការពារក្តីរបស់ជនត្រូវចោទ។

**ភ្នំពេញ ថ្ងៃទី៣០ ខែ មេសា ឆ្នាំ២០១០**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

**Rowan DOWNING** **ន៉យ ថុល** **Katinka LAHUIS** **ហួត វុធី** **ប្រាក់ គឹមសាន**

**ក្រឡាបញ្ជី**

Entela JOSIFI **ឈន ព្រលឹង**